អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# សត្វស្វាទាំងប្រាំនិងដើមចេក

# Five Monkeys and the Banana Tree



WRITTEN BY TEACHER ROBIN OF THE USA

ILLUSTRATED BY SEM RASIN



នៅក្នុងព្រៃជ្រៅមួយ មានដើមចេកមួយគុម្ពដុះច្រូងច្រាងស្លឹកតូចធំពណ៌បៃតងស្រស់។ មានសត្វស្វាប្រាំក្បាលកំពុងប្រឡែងគ្នាលេងនៅក្បែរនោះ។ សុខវ៉ា សុខវី វីណា ដារ៉ូនិងដាលីស ជាឈ្មោះរបស់ពួកវា។ ពួកវាទាំងអស់គ្នាចូលចិត្តស៊ីចេកខ្លាំងណាស់។





ថ្ងៃមួយ ពួកគេបានឃើញផ្លែចេកមួយស្ទងនៅលើដើម។ «មើលហ្ន៎! ផ្លែចេកនោះទុំពណ៌លឿង ថ្លោសៗល្អណាស់!» វីណាបានស្រែកប្រាប់សត្វស្វាឯទៀត។
«តស់! បេះផ្លែចេក!» ដារ៉ូនិយាយ។





ពួកវាបានស្រែក ហើយប្រកែកគ្នា។
«ខ្ញុំចង់បេះមួយផ្លែដែលធំជាងគេ!» សុខរីនិយាយទាំងលោតចុះ លោតឡើង។
«តែខ្ញុំចង់បេះមុន!» ដារ៉ូស្រែកបណ្ដើរ ជ្រែងចង្កេះបណ្ដើរ។
«អត់ទេៗ! ឱ្យខ្ញុំបេះមុន!» ដាលីសស្រែក ឆ្កាវដៃឆ្កាវជើង ។
«អត់ទេៗ! ទុកឱ្យខ្ញុំជាអ្នកបេះមុន!» វីណាក៏ស្រែកដែរ។





សុខរ៉ា បានស្រែកខ្លាំងៗ «ពួកយើងឈប់ប្រកែកគ្នាទៅ! ពួកយើងត្រូវតែសហការគ្នា ដើម្បីបេះវាឱ្យបាន។ ខ្ញុំនឹងឡើងទៅលើដើមចេក ហើយខ្ញុំនឹងព្យាយាមទាញវាឱ្យទ្រេតចុះមកក្រោម»។ និយាយរួច សុខរ៉ាបានឡើងចាប់ទាញស្ទងចេកទម្រេតចុះមក តាមកម្លាំងដែលអាចធ្វើទៅបាន ប៉ុន្តែដើមចេករឹងមាំណាស់មិនព្រមទ្រេតចុះមកក្រោមនោះទេ។

«វីណា! ជួយខ្ញុំផង!» សុខរ៉ាស្រែក។

[អានប្រយោគនេះឱ្យចប់សិន បន្ទាប់មកហូតចេញត្រឹមខ្សែបន្ទាត់]

វីណាបានឡើងតោងទាញ សុខរ៉ា ពួកវាទាញហើយទាញទៀត ប៉ុន្តែដើមចេកគ្រាន់តែរង្គើរមិនព្រមទ្រេតចុះមកក្រោមដដែល។ «ដារ៉ូ! មកជួយពួកយើងផង!» វីណាស្រែក។

[អានប្រយោគនេះឱ្យចប់សិន បន្ទាប់មកហូតចេញឱ្យឃើញរូបភាពពេញ១ទំព័រ]







ដារ៉ូបានឡើងតោងទាញ វីណា ពួកវាទាញហើយទាញទៀត ប៉ុន្តែដើមចេកគ្រាន់តែរង្គើរ មិនព្រមទ្រេតចុះមកក្រោមសោះ។ «ដាលីស! មកជួយពួកយើងផង!» ដារ៉ូស្រែក។

[អានប្រយោគនេះឱ្យចប់សិន បន្ទាប់មកហូតចេញត្រឹមខ្សែបន្ទាត់]

ដាលីស លោតឡើងតោងទាញ ដារ៉ូ ពួកវាទាញហើយទាញទៀត ប៉ុន្តែដើមចេកគ្រាន់តែរង្គើ មិនព្រមទ្រេតចុះមកក្រោមឡើយ។ «សុខរី! ពួកយើងត្រូវការឯងជួយ!» ដាលីសស្រែក។

[អានប្រយោគនេះឱ្យចប់សិន បន្ទាប់មកហូតចេញឱ្យឃើញរូបភាពពេញ១ទំព័រ]





 

សុខរី លោតតោងទាញ ដាលីសយ៉ាងណែន ពួកវាទាញហើយទាញទៀត។ ឥឡូវនេះ សត្វស្វាទាំងប្រាំក្បាលបានតោងគ្នាជាជួរនៅលើស្នូងចេក «ត្រៀមខ្លួនហើយឬនៅ?» សុខរ៉ាស្រែក។ «មួយ... ពីរ... បី... ទាញទាំងអស់គ្នា!»







ប្រិប! ប្រិប! ប្រិប!
ដើមចេកចាប់ផ្ដើមទ្រេតម្ដងបន្តិចៗ ហើយដួលលើដីតែម្ដង! គ្រាំង!
សត្វស្វាទាំងប្រាំក្បាលនាំគ្នាលោតចេញ។





«ហ៊ូហ៊ូ ហេហេ!» សត្វស្វាស្រែកហ៊ោកញ្ច្រៀវ។ ពួកវាបានដណ្តើមគ្នាបេះផ្លែចេក ចេញពីស្ទង។ ឈប់សិន! ឈប់សិន! សុខរ៉ាស្រែក។ «ពួកយើងត្រូវរាប់ផ្លែចេកទុំពណ៌លឿងមានប៉ុន្មានផ្លែ រួចចែកគ្នាស៊ី។»





«មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់!» សត្វស្វាបានរាប់ផ្លែចេកណាដែលទុំពណ៌លឿងចែកគ្នាម្តងមួយៗ រហូតទាល់តែអស់។ «ចេកមួយផ្លែសម្រាប់សុខរី មួយផ្លែសម្រាប់វីណា មួយផ្លែសម្រាប់ដារ៉ូ ឯមួយផ្លែទៀតសម្រាប់ដាលីស ហើយមួយផ្លែសម្រាប់ខ្ញុំ» សុខរ៉ាបាននិយាយ។ ពួកវាបានចែកនិងបកសម្បក ហើយស៊ីជាមួយគ្នារហូតអស់តែម្តង។ «ឆ្ងាញ់ណាស់! ឆ្ងាញ់ណាស់! ឆ្ងាញ់ណាស់!»
សត្វស្វាទាំងប្រាំក្បាលបានស៊ីផ្លែចេកឡើងឆ្អែតដេកអេះពោះ។
«ផ្អែមណាស់! ឆ្ងាញ់ណាស់!» ពួកវាបាននិយាយ។





សត្វស្វាទាំងប្រាំបានឱបគ្នាយ៉ាងស្និទ្ធស្នាល។ ពួកវាបានទះដៃទាំងសងខាងជាមួយគ្នា ទៅវិញទៅមកជាសញ្ញានៃភាពសាមគ្គីគ្នា។ ការចេះចែករំលែកធ្វើឱ្យចិត្តសប្បាយរីករាយ។ ឥឡូវនេះសត្វស្វាទាំងប្រាំដឹងហើយថា៖

ការចែករំលែកគឺល្អ។

ការចែករំលែកគឺសប្បាយរីករាយ។

ការចែករំលែកគឺរក្សាចំណងមិត្តភាព។






# សត្វស្វាទាំងប្រាំនិងដើមចេក

គំនូរជីវចល

ធនធានបង្រៀន

អ្នកនិពន្ធ៖ អ្នកគ្រូ រ៉ូប៊ីន

រូបភាពដោយ៖ សែម រ៉ាស៊ីន

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ R4C

TUKTUK

Kiwanis
ROCKVILLE, MD, INC.